**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១០ សរ.សរ.ខ.៧៨

# សារលិខិតជូនពរ

## សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧

**សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់**

នៅក្នុងឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លា ប្រកបដោយក្តីអភិរម្យសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤-១៥ និងទី១៦ ខែមេសា ខាងមុខនេះ តាងនាមសមាជិក សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ព្រមទាំងភរិយា សូមសម្តែងនូវសេចក្តីសោមនស្សរីករាយឥតឧបមា ចូលរួមជូននូវសព្ទសាធុការពរជ័យបវរមហាប្រសើរគ្រប់យ៉ាងចំពោះសម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ សូមបានប្រកបទៅដោយកាយពលរឹងមាំខ្លាំងក្លា បញ្ញាញាណភ្លឺថ្លា ត្រចះត្រចង់ សុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរតរៀងទៅ។ យើងខ្ញុំតែងតែនឹកឃើញនិងចងចាំជានិច្ច ប្រកបដោយការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះឆន្ទៈនិងសកម្មភាពស្នេហាជាតិ និងប្រជាជនរបស់សម្តេច ដែលបានខិតខំយកអស់កម្លាំងកាយចិត្ត បញ្ញាញាណ និងបទពិសោធន៍ ប្រកបដោយគំរូវីរភាពដ៏ខ្ពង់ខ្ពស់របស់សម្តេច ក្នុងការរួមចំណែកពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការកែទម្រង់រដ្ឋស៊ីជម្រៅលើគ្រប់វិស័យ និងការកសាងសមិទ្ធផលសង្គមយ៉ាងច្រើនដើម្បីជាឧត្តមប្រយោជន៍ចំពោះជាតិមាតុភូមិ រួមចំណែកស្តារ និងអភិវឌ្ឍទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាទីស្នេហានៃយើងទាំងអស់គ្នាឱ្យមានការីកចម្រើនជឿនលឿនយ៉ាងឆាប់រហ័សនារយៈកាលកន្លងមក។

ឆ្លៀតក្នុងឱកាសដ៏មង្គលសួស្តីវិសេសវិសាលនេះផងដែរ យើងខ្ញុំទាំងអស់គ្នាសូមលើកហត្ថប្រួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ឫទ្ធិបារមីខ្លាំងក្លា វត្ថុស័ក្តសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ពិសេសទេវតាថែរក្សាឆ្នាំថ្មី ឆ្នាំរកា នព្វស័ក ព្រះនាម **កិមិរាទេវី** សូមព្រះអង្គតាមជួយអភិបាលប្រោះព្រំសព្ទសាធុការពរជ័យគ្រប់ប្រការចំពោះសម្តេចប្រធាន និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី បុត្រប្រសា ចៅប្រុស ចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបដោយពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍តរៀងទៅ។

សូមសម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា និងលោកជំទាវ មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅ និងភក្តីភាពដ៏ស្មោះស្ម័គ្របំផុតពីខ្ញុំ និងភរិយា។ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**